**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# សូមគោរពជូន
## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
## និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**តាមរយៈ** លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**កម្មវត្ថុ៖** កិច្ចប្រជុំពិភាក្សា ស្តីពី សំណើសុំរាជរដ្ឋាភិបាលកម្ពុជាផ្តល់ការបំភ្លឺ អំពីករណីជួញដូរមនុស្សនៅកម្ពុជា

ថ្ងៃព្រហស្បតិ៍ ១០រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង៨ : ៣០ នាទីព្រឹក នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានបើកកិច្ចប្រជុំពិភាក្សា "**ស្តីពី សំណើសុំរាជរដ្ឋាភិបាលកម្ពុជាផ្តល់ការបំភ្លឺ អំពីករណីជួញដូរមនុស្សនៅកម្ពុជា**" ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី៖

១.ឯកឧត្តម នាយឧត្តមសេនីយ៍ **កែវ វណ្ណថន** អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍

២.ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខៀវ ចាន់រ៉ា** អគ្គលេខាធិការរង គ.ជ.ប.ជ

៣.ឯកឧត្តម **សួង សង្ហាវិទ្ធី** អគ្គនាយករង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

៤.ឯកឧត្តម **ជ័យ រដ្ឋា** អគ្គនាយករង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

៥.លោកស្រី **សុន សុខាលីនដា** អគ្គនាយករង ក្រសួងយុត្តិធម៌

៦.លោកស្រី ឧត្តមសេនីយ៍ទោ **ស៊ឹម ផាណុំ** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

៧.លោក ឧត្តមសេនីយ៍ទោ **ហាង ជីវ័ន្ត** ប្រធានលេខាធិការរដ្ឋបាលសរុប នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

៨.លោកស្រី **សុភា កន្និដ្ឋា** អនុប្រធាននាយកដ្ឋាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

៩.លោក **នោ បណ្ឌូល** តំណាងក្រសួងកិច្ចការនារី

១០.ប្រធាន អនុប្រធានក្រុមជំនួយកិច្ចការទាំង៦ (គ.ជ.ប.ជ) លោក លោកស្រីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សរុបចំនួន ២២ រូប ស្រី ៤ រូប។

ជាកិច្ចចាប់ផ្តើម លោកជំទាវប្រធានអង្គប្រជុំបានមានប្រសាសន៍ពាក់ព័ន្ធនឹងការចុះបង្ក្រាបបទល្មើសបង្ខាំងមនុស្សនៅតាមទីតាំងកាស៊ីណូក្នុងរាជធានីភ្នំពេញ និងខេត្តព្រះសីហនុ ដែលបានរកឃើញជនរងគ្រោះមួយចំនួន និងបានចាប់ខ្លួនជនល្មើសផងដែរ ។ លោកជំទាវ បានធ្វើការដឹកនាំសមាជិក សមាជិកាអង្គប្រជុំពិនិត្យលើសំណើពាក់ព័ន្ធការជួញដូរមនុស្សនៅកម្ពុជា ដែលមានចំនួន ១៣ ចំណុច ដែលតម្រូវឲ្យរាជរដ្ឋាភិបាលកម្ពុជាឆ្លើយតបក្នុងរយៈពេល ៦០ថ្ងៃ ។

ជាលទ្ធផល លោកជំទាវ ប្រធានអង្គប្រជុំ និងសមាជិក សមាជិកា នៃអង្គប្រជុំបានសម្រេចយកសំណើទៅពិនិត្យ និងឆ្លើយតបនូវចំណុចនីមួយៗក្នុងនាមរាជរដ្ឋាភិបាល ដែលមានភារកិច្ចទទួលខុសត្រូវរួមគ្នា ដោយផ្ញើលទ្ធផលមកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តាមរយៈប្រព័ន្ធតេឡេក្រាម(Telegram) ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃសុក្រ ១១រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ទោ. សៅ ស៊ីនួន

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃ រង្គារ ៦ កើត ខែ កត្តិក. ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា. ឆ្នាំ២០២២

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯកវេជ្ជ.ប៊ុណ្ណ សំខាន់

14/11/22